# <u>សង្កាត់សាលារៀនអកឡិនដ៍ (OUSD)</u>
## <u>បែបបទស៊ីពីការយល់ព្រម និងការព្រមព្រៀងគ្នា លើការប្រើប្រាស់គ្រឿងបច្ចេកទេសដែលអាចទទួលយកបាន</u>

យើងខ្ញុំរីករាយក្នុងការផ្តល់អោយកូនសិស្សនៃយើង នូវសិទ្ធិប្រើប្រាស់កំព្យូទ័រ បណ្តាញ និងគ្រឿងបច្ចេកទេសរបស់សង្កាត់ សំរាប់គោលបំណងនៃការអប់រំ។ មាតាបិតា ព្រមទាំងកូនសិស្ស ត្រូវបានជំរាបជូនអោយបានដឹងជាមុនថា ឯកសារខ្លះៗ ដែលពួកគេអាចទទួលបាន តាមរយៈអ៊ិនធឺណិតនោះ អាចមានអត្ថបទខុសច្បាប់ ដែលធ្វើអោយខូចកេរ្តិ៍ឈ្មោះ ដែលមានខ្លឹមសារមិនពិត ឬដែលអាចធ្វើអោយមនុស្សមួយចំនួនទាស់ចិត្ត។ សង្កាត់មិនអាចធានាថា កម្មវិធីច្រោះអត្ថបទ អាចនឹងទប់ស្កាត់បានទាំងអស់ នូវឯកសារដែលមានលក្ខណៈមិនត្រឹមត្រូវនោះទេ។

ដើម្បីអោយអាចមានសិទ្ធិប្រើប្រាស់អ៊ិនធឺណិត គណនីផ្ទុកឯកសារឌីជីថលលើបណ្តាញ ឬគណនីផ្ទុកឯកសារតាមបណ្តាញ និងអ៊ីមែល ហើយនិងគ្រឿងបច្ចេកទេសអេឡិចត្រូនិកណាមួយផ្សេងទៀតរបស់សង្កាត់បាននោះ <u>កូនសិស្ស និង មាតាបិតា/អ្នកអាណាព្យាបាល ទាំងអស់ ត្រូវតែចុះហត្ថលេខា រួចបញ្ជូនបែបបទនេះមកកាន់ទីសាលារៀនវិញ</u>។

ការអាចប្រើប្រាស់គ្រឿងបច្ចេកទេសរបស់សង្កាត់ គឺជាឯកសិទ្ធិ ពុំមែនជាសិទ្ធិទេ។ បណ្តាញអេឡិចត្រូនិចរបស់សង្កាត់ គឺជាផ្នែកនៃកម្មវិធីសិក្សា ហើយពុំមែនជាវេទិកាសាធារណៈមួយសំរាប់ការប្រើប្រាស់ជាទូទៅទេ។ អ្នកប្រើប្រាស់មិនត្រូវរំពឹងទុកថាជារបស់ឯកជននោះទេ នៅពេលណាពួកគេប្រើប្រដាប់ប្រដារ បណ្តាញ និង/ឬ អ៊ិនធឺណិត ឬឯកសាររួមទាំងអ៊ីមែលរបស់សង្កាត់ផងដែរ។ សូមអានដោយយកចិត្តទុកដាក់ លើការប្រើប្រាស់ច្បាប់ប្រតិបត្តិ និងបទបញ្ញត្តិលើការប្រើប្រាស់គ្រឿងបច្ចេកទេស ដែលអាចទទួល យកបាន ដែលមានដាក់ជូននៅក្នុងសៀវភៅមគ្គុទេសក៍សំរាប់មាតាបិតនៃសង្កាត់ OUSD។  ការបំពានលើច្បាប់ អាចទទួលរងនូវការដាក់វិន័យ។ បទបំពាននានា អាចរួមមាន៖

- ការបញ្ជូន ឬការដាក់តាំងរូបភាព ឬគំនូរក្រាបហ្វិកដែលធ្វើអោយទាស់ចិត្ត។
- ការដាក់ប្រកាស់ ឬប្រើភាសាអាសភាសគ្រោម។
- ការបៀតបៀនគេ ការធ្វើបាបអោយគេអាម៉ាស់មុខ ការគំរាមកំហែង ឬការធ្វើបាបដល់អ្នកប្រើប្រាស់បណ្តាញ។
- ការបំពានលើច្បាប់សិទ្ធិចម្លង។
- ការប្រើគណនី និងលេខសម្ងាត់របស់អ្នកប្រើប្រាស់។
- ការធ្វើអោយខូចខាតឯកសារកំព្យូទ័រ ឯកសារផ្ទាល់ខ្លួន ឬឯកសារបណ្តាញ។
- ការបើកមើលឯកសារឯកជនរបស់អ្នកប្រើប្រាស់ម្នាក់ទៀត ដោយគ្មានការអនុញ្ញាត។
- ការព្យាយាមគេចវាងពីសន្តិសុខបណ្តាញ។
- «ការសម្លុតធ្វើបាបគ្នាតាមរយៈគ្រឿងអេឡិចត្រនិច»
- ការប្រើបណ្តាញ OUDS-Net ក្នុងគោលបំណង៍ផ្សព្វផ្សាយ ឬរកផលចំណេញខាងហិរញ្ញវត្ថុបុគ្គល។

លុះត្រាតែមានការណែនាំផ្សេងៗទៀតពីបុគ្គលិកសាលារៀន បើមិនអញ្ចឹងទេ កូនសិស្សមិនត្រូវបញ្ចេញ ប្រើប្រាស់ ឬចែកចាយព័ត៌មានអត្តសញ្ញាណផ្ទាល់ខ្លួនអំពីពួកគេ ឬអំពីអ្នកដទៃទៀត ដែលប្រើប្រាស់អ៊ីមែល បន្ទប់ជជែកកំសាន្ត ឬទម្រង់ណាមួយផ្សេងទៀត ក្នុងការប្រាលយទាក់ទងគ្នាដោយផ្ទាល់ជាអេឡិចត្រនិចនោះទេ។ កូនសិស្សត្រូវប្រយ័ត្នប្រយែងផងដែរ លើការមិនបញ្ចេញនូវព័ត៌មានបែបនេះ តាមមធ្យោបាយផ្សេងទៀត ទៅអោយមនុស្សទាំងឡាយ ដែលបានទាក់ទងពួកគេ តាមរយៈអ៊ិនធឺណិត ដោយគ្មានការអនុញ្ញាតពី មាតាបិតា/អ្នកអាណាព្យាបាល របស់ពួកគេឡើយ។ ព័ត៌មានផ្ទាល់ខ្លួន រួមមាន ឈ្មោះ អាសយដ្ឋាន លេខទូរស័ព្ទ លេខសូស្យាល់ ថ្ងៃកំណើត ឬព័ត៌មានផ្សេងៗទៀតដែលអាចធ្វើអោយគេស្គាល់នរណាម្នាក់បាន។

ដោយចុះហត្ថលេខាលើកិច្ចព្រមព្រៀងគ្នានេះ ខ្ញុំ/យើងខ្ញុំ ផ្តល់សញ្ញាប្រាប់ថា ខ្ញុំ/យើងខ្ញុំ បានអានយល់ នូវច្បាប់ប្រតិបត្តិលើការប្រើប្រាស់ដែលអាចទទួលយកបាន របស់សង្កាត់សាលារៀនអូកឡិនដ៍ ហើយបានយល់ព្រមប្រព្រឹត្តតាមលក្ខខ័ណ្ឌរបស់ខ្លួន។ ខ្ញុំ/យើងខ្ញុំ យល់ហើយថា កំព្យូទ័រ ឬបណ្តាញកំព្យូទ័រ ត្រូវបានដាក់អោយប្រើប្រាស់បានតែសំរាប់គោលបំណងនៃការសិក្សាប៉ុណ្ណោះ។

### <u>ការយល់ព្រមពីកូនសិស្ស</u>

ខ្ញុំបាទ/នាងខ្ញុំ យល់ហើយថា ការប្រើប្រាស់កំព្យូទ័ររបស់ខ្ញុំ ការប្រើប្រាស់គ្រឿងបច្ចេកទេបច្ចេកទេសផ្សេងៗទៀត ខណៈនៅឯសាលារៀន  ឬតភ្ជាប់ទៅសង្កាត់ និងប្រព័ន្ធទាក់ទងគ្នា និងប្រព័ន្ធផ្ទុកឯកសារណាមួយជាអេឡិចត្រូនិក (រួមមានទាំង អ៊ីមែល និងថតផ្ទុកឯកសារ (folder) របស់កូនសិស្ស, ធនធាន ឬឧបករណ៍ផ្ទុកឯកសារសោឌីជីថល និងគេហទំព័ររបស់ថ្នាក់រៀន ឬរបស់កូនសិស្ស) គឺពុំមែនជារបស់ឯកជនទេ ហើយថាសង្កាត់មានសិទ្ធិត្រួតពិនិត្យលើសកម្មភាពរបស់ខ្ញុំ។

ខ្ញុំបាទ/នាងខ្ញុំ បានអាន ចាប់បេតិបតិ BP 6163.4 និងបទបញាតិរដបាល AR 6163.4 អំពី ការប្រើប្រាស់គ្រឿងបច្ចេកទេសនៃកូនសិស្សរបស់សង្កាត់ ហើយព្រមទាំងបានយល់ព្រមប្រតិបត្តិតាម ច្បាប់ប្រើប្រាស់គ្រឿងបច្ចេកទេសដែលអាចទទួលយកបាននេះផងដែរ។ ខ្ញុំបាទ/នាងខ្ញុំ យល់ហើយថា ការបំពានលើបទបញ្ញត្តិ និងច្បាប់ប្រតិបត្តិនេះ អាចបណ្តាលឱ្យទទួលរងនូវចំណាត់ការដាក់វិន័យ រួមទាំង ការបាត់បង់ឯកសិទ្ធិក្នុង ការប្រើប្រាស់គ្រឿងបច្ចេកទេស ការបញ្ឈប់បណ្តោះអាសន្នពីសាលារៀន ឬការបណ្តេញចេញពីសាលារៀន ឬការចាត់វិធានការតាមផ្លូវច្បាប់។

ហត្ថលេខានៃកូនសិស្ស ______________________________ ថ្ងៃខែ ____________

### <u>ការយល់ព្រមពីមាតាបិតា</u>

ខ្ញុំបាទ/នាងខ្ញុំ បានអាន *ច្បាប់ប្រតិបត្តិ និងបទបញ្ញត្តិ អំពីការប្រើប្រាស់គ្រឿងបច្ចេកទេសដែលអាចទទួលយកបាន* ដែលមានដាក់ជូននៅក្នុងសៀវភៅមគ្គុទេសក៍ សំរាប់មាតាបិតានៃសង្កាត់ OUSD។ ពីព្រោះតែឯកសិទ្ធិនៃកូនខ្ញុំ ក្នុងការប្រើប្រាស់ប្រព័ន្ធទាក់ទងគ្នាតាមគ្រឿងអេឡិចត្រូនិករបស់សង្កាត់ ហើយពីព្រោះតែការមានសិទ្ធិប្រើប្រាស់បណ្តាញសាធារណៈនោះ <u>តាមរយៈនេះ ខ្ញុំបាទ/នាងខ្ញុំ ដោះលែងសង្កាត់សាលារៀនអូកឡិនដ៍</u> ការី និយោជិក ឬទីភ្នាក់ងាររបស់ខ្លួន ហើយនិងស្ថាប័នណាមួយ ដែលពួកគេបានចូលជាសមាជិកនោះ រួចពីការទាមទារ សំណង និងការខូចខាត ដែលកើតចេញពីការប្រើប្រាស់ ឬការខ្វះសមត្ថភាពក្នុងការប្រើប្រាស់ទាំងប្រព័ន្ធ រួមទាំង ដោយគ្មានកំណត់ លើប្រភេទនៃការខូចខាតដែលបានចែងនៅក្នុងច្បាប់ប្រតិបត្តិ និងបទបញ្ញត្តិរដ្ឋបាល អំពីការប្រើប្រាស់គ្រឿងបច្ចេកទេសដែលអាចទទួលយកបាន របស់សង្កាត់។

ហត្ថលេខានៃ មាតាបិតា/អ្នកអាណាព្យាបាល ______________________________ ថ្ងៃខែ៖ ____________

ឈ្មោះកូនសិស្ស៖ ______________________________ សាលារៀន៖ ______________________________

អាសយដ្ឋានផ្ទះ៖______________________________ លេខទូរស័ព្ទផ្ទះ៖______________________________

ថ្នាក់ទី៖__________ លេខទូរស័ព្ទការងារ ឬទូរស័ព្ទដៃ៖ ______________________________ ថ្ងៃកំណើត៖ ______________________________